# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍សង្ខេប

របស់ឯកឧត្តមលឹមស៊ីដេនីន រដ្ឋលេខាធិការ និងជានាយកដឹកនាំគំពេង

ស្តីពីការសាងសង់កំណាត់ផ្លូវលេខ២១៣ ខេត្តព្រះវិហារ

ក្នុងឱកាសនៃពិធីសម្ពោធបើកការដ្ឋាន

ថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១០

សូមក្រាបថ្វាយបង្គំ ព្រះសង្ឃគ្រប់ព្រះអង្គជាទីសក្ការៈ

ព្រះថេរានុថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ

សូមគោរព

ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

ឯកឧត្តមរដ្ឋលេខាធិការ, អនុរដ្ឋលេខាធិការ

ឯកឧត្តមក្រុមប្រឹក្សាខេត្តព្រះវិហារ

ឯកឧត្តមអភិបាលខេត្ត ព្រះវិហារ

តំណាងធនាគារពិភពលោកប្រចាំនៅកម្ពុជា

តំណាងទីប្រឹក្សាបច្ចេកទេសប្រចាំគម្រោង

អស់លោក លោកស្រី បងប្អូនប្រជាពលរដ្ឋ លោកយាយជី តាជី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ជាទីមេត្រី។

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ដោយបានការអនុញ្ញាត ពី ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន អនុញ្ញាតឲ្យរូបខ្ញុំមានឱកាសថ្លែងនូវរបាយការណ៍សង្ខេបស្តីពី សកម្មភាពអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តនិងជនបទដែលហៅកាត់ថា(PRIP)ក្នុងក្រប ខ័ណ្ឌថវិកាពីធនាគារពិភពលោក ក្នុងផែនការ អភិវឌ្ឍន៍លើតំបន់អាទិភាពទី១របស់រាជរដ្ឋាភិបាល ដើម្បី ជួសជុល ស្តារនិង ថែទាំ ផ្លូវនិងស្ពានក្នុងខេត្តទាំងបួន ខេត្តកំពង់ធំ ព្រះវិហារ សៀមរាប និងឧត្តរមានជ័យ។

គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវខេត្តនិងជនបទត្រូវបានរាជរដ្ឋាភិបាលកំណត់ឲ្យមានក្រសួងពីរជាស្ថាប័នគ្រប់គ្រងគម្រោងគឺក្រសួងសាធារណការនិងដឹកជញ្ជូននិងក្រសួងអភិវឌ្ឍន៍ជនបទដើម្បី អនុវត្តការងារជួសជុលថែទាំផ្លូវជាតិ ផ្លូវខេត្ត (សំរាប់ក្រសួងសកដ)និង ផ្លូវជនបទ (សំរាប់ក្រសួងអភិវឌ្ឍន៍ជនបទ )

ដែលកន្លងមក ការធ្វើដំណើរមានការលំបាក ឬមិនអាច ធ្វើចរាចរបាន ដើម្បី តភ្ជាប់គ្នាទៅវិញទៅមកពី តំបន់ដាច់ស្រយ៉ាល ជនបទនិងទីក្រុង។

ចំនុចពិសេសរបស់គំរោង(PRIP)នេះទៀតផងដែរគឺពង្រឹងសមត្ថភាព ក្រសួងសាធារណការ និង ដឹកជញ្ជូន ពីថ្នាក់លើដល់ថ្នាក់ក្រោម ស្របទៅគោលនយោបាយរបស់រាជរដ្ឋាភិបាល អណ្តត្តិទី៤ ស្តីពី សហវិមជ្ឈការ វិមជ្ឈការ ក្នុងការជួសជុល ថែទាំ ស្តារ និង អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និង តភ្ជាប់ប្រព័ន្ធផ្លូវថ្នល់ ក្នុងខេត្តទាំង៤ ពីផ្លូវជាតិរហូតដល់ផ្លូវជនបទ អោយទៅជាបណ្តាញផ្លូវថ្នល់មានប្រសិទ្ធិភាព ក្នុងការ ដឹកជញ្ជូននិងមានភាពងាយស្រួលក្នុងការធ្វើដំណើររបស់ប្រជាជន។

គម្រោងហេដ្ឋារចនាសម្ព័ន្ធខេត្តនិងជនបទបានទទួលថវិកា ពីធនាគារពិភពលោកចំនួន ២០លានដុល្លាអាមេរិច និង ថវិកាបដិភាគ របស់រាជរដ្ឋាភិបាល ចំនួន៣លានដុល្លាអាមេរិច ក្រោម កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងធនាគារពិភពលោកនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ហើយគម្រោងបានចូល ជាធរមាន នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ កំពុងអនុវត្តមកដល់សព្វថ្ងៃហើយនិងត្រូវបញ្ចប់ក្នុង ដំណាច់ឆ្នាំ២០១១ខាងមុខ។

**ឯកឧត្តម អស់លោក លោកស្រី**

គម្រោងហេដ្ឋារចនាសម្ព័ន្ធខេត្តនិងជនបទ ជួយធ្វើឲ្យប្រសើរឡើងនូវស្ថានភាពគ្រប់វិស័យក្នុងខេត្ត ទាំងបួន (កំពង់ធំ ព្រះវិហារ សៀមរាប និង ឧត្តរមានជ័យ) និងបានបែងចែកជា ៥ផ្នែកសំខាន់ៗគឺ:

១-ការងារថែទាំផ្លូវថ្នល់ជាប្រចាំ

២-ការងារជួសជុល ស្តារឡើងវិញនិងថែទាំខួបលើផ្លូវជាតិពីរលេខនិងផ្លូវខេត្ត សំរាប់ក្រសួង សាធារណការនិងដឹកជញ្ជូន និង ផ្លូវជនបទសំរាប់ក្រសួងអភិវឌ្ឍន៍ជនបទ។

៣-ពង្រឹងសមត្ថភាពដល់មន្ត្រីមន្ទីរខេត្តទាំងបួន និងមន្ត្រីនាយកដ្ឋានផ្លូវថ្នល់

៤-អភិវឌ្ឍន៍យុទ្ធសាស្ត្រ និងនយោបាយផ្លូវថ្នល់ (ពលកម្មជាមូលដ្ឋាន លទ្ធផលជាមូលដ្ឋាន)

៥-ចំណេះដឹងសាធារណៈដោយធ្វើការផ្សព្វផ្សាយសុវត្ថភាពផ្លូវថ្នល់ គ្រោះថ្នាក់ចរាចរណ៍ និងផ្សព្វផ្សាយអំពីផលប៉ះពាល់ពីជម្ងឺឆ្លង។

ជាការចាប់ផ្តើម ក្នុងឆ្នាំ២០០៤ គម្រោងក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន បានធ្វើការសិក្សា ធ្វើផែនការ ការស្តារជួសជុលឡើងវិញនិងថែទាំផ្លូវក្នុងខេត្តទាំងបួនដោយជ្រើសរើស គំរោងតាមអាទិភាពដោយប្រមូលផ្តុំមតិយោបល់របស់ប្រជាជន សហគមន៍ ភូមិឃុំ ស្រុកខេត្តនៅមូលដ្ឋាន បាន លើកផែនការ សរុបផ្លូវ ត្រូវអនុវត្តន៍ ចំនួនផ្លូវជាតិចំនួន២៤៦,៨៥គម, ផ្លូវខេត្ត១៤៧,៤គម ដែល ក្នុងនោះមានផ្លូវក្រាលកៅស៊ូចំនួន៩៤,៣៥គម, ក្រាលដីគ្រួសក្រហមចំនួន ៣០០គម។ តាមការសំរេច

របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និង មូលដ្ឋានថ្នាក់ក្រោមបានឯកភាពគ្នា សំរាប់គំរោង (PRIP) ធ្វើការជួសជុល ស្តាផ្លូវ ចំនួន៣០០ គ.ម ។

ក្នុងឆ្នាំទី១នៃគំរោងយើងអនុវត្តន៍បាន៖

-ផ្លូវក្រាលកៅស៊ូ ៩២ គ.ម

-ផ្លូវក្រាលដីគ្រួសក្រហម ១៥០ គ.ម

-ស្ពានគ្រប់ប្រភេទ១៧០ម

-ថែទាំផ្លូវគ្រប់ប្រភេទ ១១០ គ.ម

សរុបការងារធ្វើបាន ៖ ២៤២គ.ម ស្មើនិង ៨១ ភាគរយ នៃផែនការ ។

ក្នុងដំណាក់កាល ឆ្នាំទី២នៃគំរោងនេះ ផ្លូវខាងលើទាំងនោះ នៅមិនទាន់ អាចតភ្ជាប់បាន១០០ភាគរយនៅឡើយទេ។ ដើម្បីបំពេញសេចក្តីត្រូវការនៃចរាចរ គម្រោងត្រូវធ្វើការជ្រើសរើសផ្លូវបន្ថែមជាអាទិភាពទៀតសំរាប់អនុវត្ត ដែលភាគច្រើនជាផ្លូវដែលត្រូវភ្ជាប់ពីតំណាក់កាលមុន ព្រោះទិសដៅគម្រោងគឺធ្វើឲ្យបណ្តាញផ្លូវទាំងអស់តភ្ជាប់គ្នាពីផ្លូវជនបទទៅកាន់ផ្លូវខេត្តនិងពីផ្លូវខេត្តទៅកាន់ផ្លូវជាតិ។ដូចនេះ គម្រោងបានបន្ត ស្តារ ជួសជុល និងថែទាំ មានផ្លូវខេត្តនិងជនបទតាមផែនការគំរោងនិងអាទិភាពដែលបានកំណត់បន្តទៀត។ ពិសេសជាងនេះទៀត គំរោងផ្លូវខេត្តផ្លូវជនបទនេះ បានជួយសម្រួល និង បង្ករលក្ខណៈធ្វើអោយដៃគូរអភិវឌ្ឍន៍ផ្សេងៗទៀតរួមមាន គំរោងថៃ គំរោងចិន គំរោងកូរ៉េ គំរោងADB និងគំរោងជាតិចូលរួមអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទទួលបាននូវសមិទ្ធិផលល្អប្រសើ មានលទ្ធភាពធ្វើការតភ្ជាប់កំណាត់ផ្លូវ ធ្វើឲ្យបណ្តាញផ្លូវថ្នល់ក្នុងខេត្តទាំងបួន បង្កើតបានជាបណ្តាញប្រព័ន្ធផ្លូវមួយមានប្រសិទ្ធិភាពសុវត្ថិភាព បានល្អស្ទើរតែ១០០%។

**ឯកឧត្តម អស់លោក លោកស្រី ជាទីគោរព**

**បងប្អូនប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ជាទីស្រឡាញ់**

កំណាត់ផ្លូវរបស់ផ្លូវខេត្តលេខ២១៣ ប្រវែង៧៩.១៧៧គម ដែលតភ្ជាប់ពីផ្លូវជាតិ៦២ (ភ្នំដែក) ទៅផ្លូវខេត្ត២១២(ទីរួមស្រុកថែប) ដែលជាកំណាត់ផ្លូវមានសារៈសំខាន់បំផុតក្នុងការដឹកជញ្ជូន កសិកម្ម ឧស្សាហកម្ម និង សមហារកម្មជាតិ៣ស្រុក ស្រុកថែប ស្រុកជ័យសែន និង ស្រុករវៀង និងជាពិសេសអាចអោយប្រជាជនធ្វើ ដំណើក្នុងរដូវវស្សាបាន ដែលពីមុនមិនអាចធ្វើបាន។ ដោយឡែកផ្លូវដែលត្រូវធ្វើពិធីសម្ពោធបើកការដ្ឋាននាថ្ងៃនេះគឺៈកំណាត់ផ្លូវតភ្ជាប់ពីផ្លូវចុងកៅស៊ូផ្លូវខេត្ត២១៣ទៅកាន់ស្ពានកំពង់ព្រទ្រាមានប្រវែងសរុប១៨គម ។ ជាកំណាត់ផ្លូវដែលត្រូវសាងសង់ថ្មីដោយលើកកំពស់តួថ្នល់បន្ថែមនិងក្រាលកៅស៊ូពីរជាន់ DBST ទទឹង ៦,០ម៉ែត្រ ចិញ្ចើមសងខាង ២ម៉ែត្រតាមរូបមន្ត (២ម +២ម X២ )

សាងសង់ស្ពានបេតុងមួយកន្លែង ប្រវែង៥០ម៉ែត្រ ទទឹង ៨ម៉ែត្រ លូជ្រុងចំនួន១កន្លែង នឹងលូមូលចំនួន២២កន្លែង ដោយប្រើទឹកប្រាក់អស់ចំនួន ៣,៣៧៨, ២០៨ ដុល្លាអាមេរិច អនុវត្តន៍ដោយក្រុមហ៊ុនសុខសុខា។

នេះជារបាយការណ៍សង្ខេប ដើម្បីរាយការណ៍ជូនព្រះអង្គ គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី មេត្តាជ្រាប ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធិពរជូនដល់គណៈអធិបតី ឯកឧត្តម អស់លោក លោកស្រី ព្រមទាំងប្រជាពលរដ្ឋ សិស្សានុសិស្សទាំងអស់ ជួបប្រទះតែសេចក្តីសុខនិងសុភមង្គលគ្រប់ៗគ្នា។

សូមអរព្រះគុណ, សូមអរគុណ។